**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តស្វាយរៀង**

លេខៈ១៧១ /ល.ខ

ស្វាយរៀង.ថ្ងៃទី០៧ខែមិថុនា ឆ្នាំ ២០១១

សាលាក្រុងបាវិត
ទទួល
លេខ ១៥៥
ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១១

**ជម្រាបមក**
**លោកអភិបាលក្រុងបាវិត**

**កម្មវត្ថុ** : ស្តីពី ការធ្វើប្រតិភូកម្មលើការងារនីត្យានុកូលកម្ម ( ថតចម្លងឯកសារផ្លូវការផ្សេងៗ ) ទៅឱ្យក្រុងបាវិត នៃការិយាល័យច្រកចេញចូលតែមួយ ។

**យោង** : -សេចក្តីសម្រេចលេខ១២ សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយនិងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង-ស្រុក របស់រាជរដ្ឋាភិបាលកម្ពុជា ។
-ប្រកាសលេខ ៩២៨ប្រ.ក ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ក្រុង ស្រុក ខណ្ឌ គោលដៅ ។
-លិខិតលេខ ៦៩៣ ស.ជ.ណ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ របស់ក្រសួងមហាផ្ទៃ ស្តីពីការធ្វើប្រតិភូកម្មលើការងារ នីត្យានុកូលកម្មលើឯកសារថតចម្លងផ្សេងៗ ទៅឱ្យក្រុងគោលដៅដែលមានការិយាល័យច្រកចេញចូលតែមួយ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមជម្រាបមកលោកអភិបាលក្រុងជ្រាបថាៈ រដ្ឋបាលខេត្តនឹងធ្វើប្រតិភូកម្មលើការងារនីត្យានុកូលកម្ម( លើការថតចម្លងឯកសារផ្លូវការផ្សេងៗ) ទៅឱ្យការិយាល័យច្រកចេញចូលតែមួយក្រុងបាវិត សម្រាប់អនុវត្តក្នុងឆ្នាំ២០១១ នៃគម្រោងច្រកចេញចូលតែមួយ ដែល នឹងត្រូវដាក់ឱ្យដំណើរការក្នុងអំឡុងត្រីមាសទី២ឆ្នាំ២០១១នេះ។ ការធ្វើប្រតិភូកម្មលើឯកសារថតចម្លងទាំងនេះ គឺស្ថិតក្នុងក្របខណ្ឌនៃច្បាប់ស្របតាមបទប្បញ្ញត្តិលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ( ក្នុងនោះវិស័យនីត្យានុកូលកម្ម ដូចមាន ក្នុងឧបសម្ព័ន្ធជូនភ្ជាប់មកជាមួយ) ។

អាស្រ័យហេតុនេះសូម លោកអភិបាលក្រុងបាវិត ត្រៀមលក្ខណៈសម្បត្តិឱ្យបានគ្រប់គ្រាន់សម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាព ។

ជ. អភិបាលខេត្ត
អភិបាលរង

ម៉ែន ភិបុល

**ចម្លងជូនៈ**

- ក្រសួងមហាផ្ទៃ
  ( ដើម្បីគោរពជូនជ្រាប)
- មន្ទីរ អង្គភាពពាក់ពន្ធ័
- ឯកសារ-កាលប្បវត្តិ

single entraed

## វិស័យនីត្យានុកូលកម្ម

| ល.រ | ប្រភេទឯកសារ |
|---|---|
| ១ | - វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា |
| ២ | - វិញ្ញាបនប័ត្របណ្ដោះអាសន្នមធ្យមសិក្សាកំរិត ១ |
| ៣ | - វិញ្ញាបនប័ត្របណ្ដោះអាសន្នមធ្យមសិក្សាកំរិត ២ |
| ៤ | - វិញ្ញាបនប័ត្របណ្ដោះអាសន្នមធ្យមសិក្សាបឋមភូមិ |
| ៥ | - វិញ្ញាបនប័ត្របណ្ដោះអាសន្នមធ្យមសិក្សាទុតិយភូមិ |
| ៦ | - វិញ្ញាបនប័ត្របញ្ចប់ការសិក្សាថ្នាក់ទី ១២ |
| ៧ | - វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម |
| ៨ | - វិញ្ញាបនប័ត្រប្រកបអាជីវកម្ម |
| ៩ | - វិញ្ញាបនប័ត្របណ្ដោះអាសន្នថ្នាក់បរិញ្ញាប័ត្រ |
| ១០ | - វិញ្ញាបនប័ត្រ |
| ១១ | - លិខិតបញ្ជាក់លទ្ធផលនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ |
| ១២ | - សញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ( បំពេញវិជ្ជា) |
| ១៣ | - សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ |
| ១៤ | - សញ្ញាប័ត្រមធ្យមសិក្សាគរុកោសល្យ |
| ១៥ | - សញ្ញាប័ត្រមធ្យមសិក្សា |
| ១៦ | - សញ្ញាប័ត្រគ្រូបង្រៀនកំរិតឧត្តម |
| ១៧ | - ព្រឹត្តិប័ត្រលទ្ធផលសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ |
| ១៨ | - បរិញ្ញាប័ត្រ |
| ១៩ | - បរិញ្ញាប័ត្ររង |
| ២០ | - លិខិតបញ្ជាក់ការសិក្សា |
| ២១ | - អត្តសញ្ញាណប័ណ្ណ |
| ២២ | - សៀវភៅស្នាក់នៅ |
| ២៣ | - ប័ណ្ណសំគាល់យានយន្ត |
| ២៤ | - ព្រឹត្តិប័ត្រពិន្ទុ |
| ២៥ | - ពាក្យសុំបញ្ជាក់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ចំណេះដឹងទូទៅ |
| ២៦ | ........................................................................................................ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តស្វាយរៀង
លេខ [illegible]

ស្វាយរៀង.ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ២០១១

# សេចក្តីណែនាំ

## ស្តីពី

## ការកំណត់តម្លៃលើវិស័យនីត្យានុកូលកម្ម

-យោងលិខិតលេខ ២៩៣ សជណ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ របស់ក្រសួងមហាផ្ទៃ ។

-យោងលិខិតលេខ ១៧១ ល.ខ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ របស់សាលាខេត្តស្វាយរៀង ។

យោងតាមការចាំបាច់ចំពោះមុខដើម្បីឲ្យការធ្វើប្រតិភូកម្មលើការងារនីត្យានុកូលកម្មមានតម្លាភាព និង បម្រើបានតាមសេចក្តីត្រូវការជាក់ស្តែងជូនប្រជាពលរដ្ឋនោះ អភិបាលខេត្តសូមធ្វើការកំណត់តម្លៃសេវាកម្ម រដ្ឋបាលជូនសាលាក្រុងបាវិតដូចខាងក្រោម ៖

១. ការបញ្ជាក់ការសិក្សា ឬសញ្ញាបត្រផ្សេងៗចំនួន ០៥សន្លឹក តម្លៃ ៣.០០០រៀល "បីពាន់រៀល"ដោយបូករួមនឹងតម្លៃ តែមប្រិ៍សារពើពន្ធ ។

២. ប័ណ្ណសម្គាល់យានយន្ត សៀវភៅស្នាក់នៅ អត្តសញ្ញាណប័ណ្ណ ចំនួន ០៥សន្លឹក តម្លៃ ៣.០០០រៀលគត់ "បីពាន់រៀល" ដោយបូករួមនឹងតម្លៃតែមប្រិ៍សារពើពន្ធ ។

៣. វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម តម្លៃ ១២.០០០រៀល "ដប់ពីរពាន់រៀល" ដោយបូករួមនឹងតម្ល តែមប្រិ៍សារពើពន្ធ ។

៤. វិញ្ញាបនប័ត្រប្រកបអាជីវកម្ម (ប័ណ្ណប៉ាតង់) តម្លៃ ១៥.០០០រៀល "ដប់ប្រាំពាន់រៀល" ដោយបូករួម នឹងតម្លៃតែមប្រិ៍សារពើពន្ធ ។

-ចំពោះថវិកាទាំងនេះ ត្រូវបង់ចូលរតនាគារខេត្តស្របតាមគោលការថវិកា ។ ទទួលបានការណែនាំនេះ សូមលោកអភិបាលក្រុងចាត់ចែងបិទផ្សាយ ផ្សព្វផ្សាយ និងអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ។

អភិបាលខេត្ត

ជៀង_អំ

ចម្លងជូន
-ក្រសួងមហាផ្ទៃ
*(ដើម្បីគោរពជូនជ្រាប)*
-រតនាគារខេត្ត *(ដើម្បីមុខការ)*
-ឯកសារ-កាលប្បវត្តិ